HONEYCOMB 2/1 (January 2001): 42–55



# Introduction to Philemon

*Russell H. BOWERS, Jr.*

## Background

None of Paul's letters receives less attention than Philemon. Yet none more clearly illustrates the gospel.

Philemon was penned to an individual, unlike Romans through Thessalonians. It concerns personal rather than church matters, unlike Timothy and Titus. It is the shortest of Paul's extant letters. It thus stands unique.

Philemon is one of Paul's prison epistles, along with Ephesians, Philippians, and Colossians.[1] Among these four, Colossians and Philemon stand in particularly close relation.[2] The imprisonment is probably Paul's house arrest described in Acts 28, thus dating these letters around AD 60–61. This is an earlier imprisonment from the one alluded to six years later in 2 Timothy.[3] In the earlier letters Paul expected—and was apparently granted—release, but in 2 Timothy the apostle knew that his martyrdom drew near (4:6). This time he was not under relatively comfortable house arrest but chained (2:9) in a cold dungeon (4:13).

---

[1]See Eph 3:1; 4:1; 6:20; Phil 1:13–14; Col 4:10; Phm 1, 23.

[2]See references to Epaphras in Col 1:7; 4:12; and Phm 23; to Archippus in Col 4:17 and Phm 2; to Luke and Demas in Col 4:14 and Phm 24; and to Mark and Aristarchus in Col 4:10 and Phm 24. Onesimus—the slave who is the subject of the letter to Philemon—is one of the bearers of both Colossians (4:9) and Philemon (12). These two letters were apparently written and sent at the same time.

[3]See 1:16–17; 2:9; 4:6–8, 13.

Paul's imprisonment alluded to in 2 Timothy, however, does not concern us here. During his earlier Acts 28 house arrest, the apostle apparently met a runaway slave named Onesimus and led him to faith in Christ (see Phm 10). Possibly Onesimus had stolen from his owner as well as running away (Phm 18). But even if he had not, he still owed his master Philemon the labor he would have rendered all the time he was AWOL. In first-century Rome slaves were considered the property of their masters, who could execute them with impunity for such crimes. Nevertheless, the right thing for the new Christian Onesimus to do was return to his owner, despite this death threat which hung over his head. So Paul wrote the short letter in our Bible to Philemon to urge him to receive and forgive his slave.

## Brief Commentary

**Paul Greets his Readers (1–3).** Paul is going to make an entreaty in this letter, so he does not begin by using his authoritative title "apostle." He is of course an apostle. And he has no qualms about calling himself such and asserting his Christ-given authority where necessary.[4] But because in the present case he will appeal to Philemon's heart, he lays his authority aside. He refers to himself as a "prisoner," a title more likely to elicit Philemon's sympathetic attention to his request.

The letter is addressed to Philemon (a believing Colossian slave-owner), to Apphia (possibly Philemon's wife), to Archippus (whom Paul calls his "fellow soldier"),[5] and to the church which met in his house.

**Paul Expresses Thanks and Prayers for his Readers (4–7).** The seasoned apostle knows the difference between genuine praise and

---

[4]Paul employs the title "apostle" in the greetings of all his NT epistles except Philippians, Thessalonians, and Philemon. His tone is unapologetically strident throughout the letter to the Galatians, and he threatens to use authority in 2 Cor 13:10.

[5]In Col 4:17 Paul urges Archippus to "complete the work [he has] received in the Lord."

flattery. He eschews the latter[6] but is never embarrassed to offer the former.[7] How encouraging to have a mentor genuinely thank God for one's fellowship, faith, and service! And how it prepares the heart to receive further counsel and consider new opportunities. Paul's praise in these verses is substantive enough to be warm and personal, but not so effusive that it appears contrived or manipulative.

Philemon is in Paul's prayers: first, the apostle hears of Philemon's faith in Christ and love for the saints[8] and so gives thanks; second, he asks that Philemon thoroughly grasp[9] every good thing we have in Christ, so that the sharing (κοινωνία) of his faith may come to be (γένηται) effective (ἐνεργής). I

---

[6]1 Thess 2:5.

[7]Paul typically begins his letters with thanks for the recipients, or at least includes commendation somewhere within them. He does this even for churches he has not met (Romans, Colossians) and those beset by problems (1 Corinthians). This pattern causes the letter to the Galatians—who were in danger of deserting the gospel for the law—to stand out in contrast.

[8]Literally "your love and faith which you have in the Lord Jesus and toward all the saints" (σου τὴν ἀγάπην καὶ τὴν πίστιν, ἣν ἔχεις πρὸς τὸν κύριον Ἰησοῦν καὶ εἰς πάντας τοὺς ἁγίους). The NIV and other translations view this verse as a chiasm, or an *ab:ba* arrangement. Thus the "love" is shown toward "the saints," and the "faith" is placed in "the Lord Jesus." Chiasm is a frequent literary device in the scriptures. In fact, the whole letter to Philemon may be viewed chiastically. See Appendix.

[9]Although ἐπίγνωσις and ἐπιγινώσκω are sometimes synonymous with γνῶσις and γινώσκω, the force of the root is on other occasions strengthened by the addition of the preposition ἐπί. In such cases, the verb signifies *know exactly, completely, through and through* [BAG] or *to possess more or less definite information about, possibly with a degree of thoroughness or competence—'to know about, to know definitely about'* [Louw-Nida]. Such is the force here. Certainly Philemon knows something of the good things we have in Christ; Paul prays that he enjoy a fuller, deeper grasp of these.

suggest that this is the preferable understanding of this verse. Paul prays that Philemon's increased understanding cause the sharing of his faith to be more fruitful. The NIV inverts this sequence, so that Philemon's sharing of his faith increases his understanding. While both are true—witness increases our knowledge, and greater knowledge makes our witness more effective—it is the latter interpretation that better fits both the grammar of this verse[10] as well as the general Pauline sequence that knowledge precedes fruitfulness.[11]

Paul concludes his praise of Philemon by telling him how much joy and encouragement he has brought his old friend, by calling him "brother," and by noting how he has refreshed other believers.

**Paul Requests that Philemon Receive and Forgive Onesimus (8–22).** The apostle will not use his authority to force Philemon's hand. Rather, he appeals to the slave owner on the basis of (1) love, (2) his own advanced age, (3) his pitiable status as a prisoner of Christ, (4) his relationship to Onesimus as "father," and (5) his warm attachment to Onesimus ("my very heart," v. 12). His request is bold. Runaway slaves enjoyed no legal protection. When found they were often beaten unmercifully or assigned to tasks which would greatly reduce their life expectancy. By asking that Onesimus be restored without punishment Paul is asking Philemon to contravene Roman culture. Such a step would grant unaccustomed human dignity to slaves, and would challenge prevailing economic and social views. Nevertheless, this is precisely what Paul asks.

He appeals "for my son Onesimus, who became my son while I was in chains." "Onesimus" (Ὀνήσιμος)—meaning "useful" or "profitable"—was a common name for slaves.

---

[10]The NRSV, for example, preserves this sequence by translating, "I pray that the sharing of your faith may become effective when you perceive all the good that we may do for Christ." The *perceiving* precedes and is the basis for the *effectiveness* of witness.

[11]See, e.g., Col 1:9–12.

"Useful" was formerly "useless" (ἄχρηστον) but now that he is a Christian has become "useful" (εὔχρηστον). The mild humor of this play on words was designed to further incline the offended Philemon to hear Paul's request.

The prisoner would like to keep the now useful Onesimus as his aide, but prefers that any good Philemon might do should be done freely rather than under coercion. So he sends him back. Verses 15 and 16 draw together pairs of opposites—*separated* but now *have him* back; *for a little time* but now *for good*; *not as a slave* but now *as a dear brother*. These opposites illustrate the good changes brought about when people believe the gospel.

After thus carefully preparing the soil of Philemon's heart, Paul finally voices his request in verse 17. All that has gone before has merely set the stage for this climactic appeal. If you consider me a partner,[12] Paul says, welcome him as you would welcome me. Because of the vast difference in status between slaves and their masters, and thus how the culture assumed an aggrieved slaveholder would treat his runaway, Paul's is an astounding request. By granting such humanity and dignity to a repentant slave, it flies in the face of and condemns the inhumane values of the day. Christian faith often does that.

But what about Onesimus' debt? That is settled as well—it is to be charged to Paul's account. Then as now a signed debtor statement carried great legal weight, and the apostle personally pens that he will repay it. But of course, since Paul had led him to faith in Christ, Philemon owed the apostle his very self. Through the gospel brought by Paul Philemon's debt of sin and damnation has been paid; how then can he extract from the apostle this

---

[12]The word is κοινωνός, "companion, partner, sharer; one who participates with another in some enterprise or matter of joint concern." The idea of a common enterprise in which people jointly invest and participate, and which lies at the root of this word and its cognates, goes far beyond the purely social connotation of "fellowship" (κοινωνία) which is often found in English. Paul and Philemon were partners in believing and promoting the gospel of Christ.

assumed monetary debt? Clearly, Paul is asking Philemon to bear the brunt of Onesimus' wrong and forego any compensation.

The difficult request has been made. Philemon weighs Paul's words. As he stands, letter in hand, returned runaway at his feet, Paul urges him to step over the line: "Yes, brother, may I enjoy benefit from you in the Lord." The word translated "may enjoy benefit" comes from the same root as the name Onesimus,[13] and continues the apostle's playful use of the slave's name. Further, Philemon has refreshed the hearts of the saints (v. 7); how can he fail to do the same for the one who introduced him to Christ (v. 20)? Nudging him further, Paul expresses his confidence that Philemon will do not only what he asked, but even more.[14] If Philemon still hesitated to comply, he soon knew that he would have to personally explain to Paul why he did not, since the prisoner hoped to soon visit him.

Did Philemon forgive Onesimus as Paul requested? We don't know. But the fact that this letter was included in the Bible suggests that he did. Interestingly, a few decades later Ignatius warmly refers to the bishop of nearby[15] Ephesus: ". . . Onesimus, a man of inexpressible love, and who is your bishop, whom I pray you by Jesus Christ to love, and that you would all seek to be like him. Blessed be God, who has granted unto you, who are yourselves so excellent, to obtain such an excellent bishop."[16] It is interesting to speculate that the forgiven slave went on to serve the church in a worthy and significant way.

---

[13]ὀναίμην is a 2nd aorist middle optative form from the verb ὀνίνημι, meaning in the middle voice *to be the recipient of help or favor, to have profit or advantage, derive benefit, have enjoyment or delight.* The optative mood was often used to express a wish or prayer.

[14]Paul perhaps hoped that Philemon would emancipate Onesimus, but never openly asked him to do that.

[15]Ephesus was about 160 km. west-northwest of Colossae in the Roman province of Asia.

[16]Ignatius to the Ephesians, ch. 1.

**Paul Passes on the Greetings of Others (23–25).** Paul closes his letter by passing on the greetings of other believers. Epaphras had evangelized Colossae and continued to pray for the church's maturity.[17] Mark, whom Paul earlier had rejected as a member of the second missionary journey,[18] is once again considered one of the apostle's "fellow workers." Aristarchus was a Thessalonian who was arrested in the riot at Ephesus, and who accompanied Paul in his journeys to Jerusalem and Rome.[19] Demas, though called here Paul's fellow worker, later deserted him because of his love for the present world.[20] Luke was the Gentile physician who authored Luke and Acts.

## Theological and Practical Counsel

**Illustrating the Gospel.**




As the diagram above illustrates, the relationship between Paul and Philemon was one of mutual partnership and respect. On the other hand Philemon was Onesimus' owner and master; Onesimus had wronged his master, making him liable to death at his hand.

---

[17]Col 1:7; 4:12–13.
[18]Acts 15:36–41.
[19]Acts 19:28–29; 20:4; 27:2.
[20]2 Tim 4:10.




However, Paul offered Onesimus to intercede with Philemon on his behalf and pay his debt. Onesimus then took his life in his hands and trusted in Paul—that his intercession would prove acceptable to Philemon and his life would be spared—and returned to his master.




Paul requested that Philemon make two simultaneous transfers. First, Philemon charges Onesimus' debt to Paul's account: "If he has done you any wrong or owes you anything, charge it to me. I, Paul, am writing this with my own hand. I will pay it back. . . ." Second, the slave owner takes Paul's status and grants it to Onesimus: "Welcome him as you would me." Although in the letter this status request precedes the one regarding debt, logically it follows the settlement of the debt question.

This exchange mirrors the redemption sinners find in Christ.




The relationship between God and Christ is one of profound oneness and partnership. Jesus himself spoke of this when he asserted, "I and the Father are one (John 10:30)." The two are not identical, but intimately and inseparably united. The underlying relationship between God and each human is that of creator and hence master. But since all in Adam are sinners by nature and by choice, they stand before him as debtors threatened with eternal death.




Out of mercy, Christ intercedes for each sinner. He first offers to pay the sin-debt of each: Christ came "to give his life as a ransom for many";[21] "God made him who had no sin to be sin for

---

[21]Mark 10:45, often considered to be the theme verse for this gospel. The word *ransom* (λύτρον) means *price or means by which*

us" (2 Cor 5:21); "Jesus . . . suffered death, so that by the grace of God he might taste death for everyone" (Heb 2:9); "he was pierced for our transgressions, he was crushed for our iniquities; the punishment that brought us peace was upon him, and by his wounds we are healed . . . Yahweh has laid on him the iniquity of us all" (Isa 53:5–6). Jesus likened salvation to release from debt.[22] Having paid the sinner's debt, he further offers to confer on him his own status before the Father: "so that in him we might become the righteousness of God" (2 Cor 5:21); "It is because of him that you are in Christ Jesus, who has become for us wisdom from God—that is, our righteousness, holiness, and redemption" (1 Cor 1:30); we are "in Christ" and authorized to pray "in Jesus' name." What is required of the sinner is that he or she exercise faith in the relationship between Christ and the Father, and in the acceptability of the payment Christ has made, and approach the Father in Jesus' name for the promised forgiveness and new relationship as son or daughter.




*release is made possible.* 1 Tim 2:6 uses the term ἀντίλυτρον. Both imply payment. See also 1 Cor 6:20; 1 Pet 1:18f.

[22]Matt 18:21–27; Luke 7:40–50; Matt 6:12.

When such faith is exercised, God judicially transfers the sinner's debt to Christ and Christ's righteousness and acceptability to the sinner.

If Philemon obeyed Paul's request, his forgiveness and acceptance of Onesimus would illustrate the gospel to all who came to know about it. It would cost Philemon to forgo his "rights"—both in lost finances and in lost opportunity for personal revenge. But his life would forever after provide a living example of how Jesus heals relationships. The New Testament frequently urges Christians to similarly "act out" the gospel in their relations with others.[23]

**Diplomacy.** There are those who believe that power and position give those who possess them the right to run roughshod over all "beneath" them. That it is theirs to command and others' to obey. That the higher one rises in rank the more one impresses others by ruling through decree. Philemon negates such assumptions.

Paul was an apostle commissioned by the risen Christ. Yet here he lays aside that authority to entreat an old friend. He will not force Philemon's hand; he declines to command him. He will appeal based on the nature of the gospel and on the relationship they enjoy. In this way, any good that Philemon does will be his own choice and therefore commendable. Philemon will get the credit, not Paul. At the same time Paul has left himself vulnerable: Philemon could ignore his request and leave him no further leverage to force the issue. Paul's "leadership" could then be discredited. But he was willing to make himself appear weak so that Philemon by his free magnanimous deed could appear strong.

Thus the letter is valuable for not only teaching *what* is the right thing to do, but also *how* to approach people to do it. Because Paul's praise of Philemon was deserved and sincere, it is not toady ingratiation. A strong leader feels free to praise his people when it is proper and build them up; he does not exalt himself over them and push them down. How much more smoothly many churches

---

[23]See, e.g., Eph 4:32; 5:22, 25.

would function if its leaders would employ the statesmanship and diplomacy evidenced in Paul's letter to Philemon.

**Affirming a substitutionary sense to *hyper*.** The Greek New Testament often uses the preposition *hyper* (ὑπέρ) to speak of Christ's dying *for* the world.[24] It is sometimes alleged that this preposition means only "for the benefit of, on behalf of," and never bears the substitutionary sense "in place of, instead of." Thus Christ's death would somehow *benefit* the world without having been made *in its place*. However, Paul uses *hyper* in Philemon 13 when he says, "I would have liked to keep him with me so that he could *take your place* in helping me. . . ." Clearly *hyper* is used here in a substitutionary sense. Onesimus's serving Paul would in no way *benefit* Philemon; it would, in fact, inconvenience him by depriving him of the services of his slave. Paul is implying that, had he had the chance, Philemon would have personally served Paul in prison. But since he is not there, Onesimus can serve *in his place*.

Therefore, although we neither can nor should *compel* *hyper* to be understood substitutionally every time it speaks of the death of Christ, that meaning must be entertained as at least lexically *possible* and *contributory*.

**Christian Holism and Social Issues.** An individual's Christian faith should influence every area of his or her life. The Bible does not encourage us to "believe" our faith only in some isolated compartment of our minds, but rather to allow it to shape how we think and act toward every issue. Thus Philemon's faith, not current Roman practice, should determine how he treats his returned runaway slave Onesimus. Christian faith is holistic in the sense that it should influence or direct every aspect of a believer's life. This short letter illustrates that truth.

But Philemon also illustrates the New Testament pattern toward confronting social ills in the larger society. Slavery—

---

[24]E.g., Mk 14:24; Jn 10:11, 15, 50–52; 15:13; 18:14; Rom 5:6–8; etc.

especially as practiced in pagan societies unregulated by the Mosaic Law—is demeaning to humans made in the image of God, exploitative, violent, and brutal. It has been for centuries a scourge crying for eradication.

Nevertheless, the New Testament as a whole and Philemon in particular says nothing about Christian responsibility to overthrow the system of slavery. No protests are organized, no letters written, no committees formed, no protest made to the government. Paul simply says, "Philemon, treat your slave as a Christian brother." Elsewhere he urges slaves to serve faithfully, and slave owners to treat their slaves fairly.[25] Christians are to act in every area of their lives as Christians, and the church is to conduct itself in every way as Christians, but society at large is never the focus of New Testament admonition. Jesus did not himself attempt or direct others to correct pagan society, nor did the apostles. We are salt and light which show by example and create thirst, not whips and scourges to compel the unconvinced. Paul makes it clear that the church's business is the church, not civil government: "What business is it of mine to judge those outside the church? Are you not to judge those inside? God will judge those outside" (1 Cor 5:12–13).

Had Christians campaigned against slavery—or any other ill in Roman society—it would have confused the gospel. Apart from God's grace, it may have proved suicidal if slaves were thereby encouraged to revolt. The Christian method is to change people's hearts and then teach the converted (individual and church) how that change should manifest itself in every relationship. The New Testament teaches discipling individuals and churches, and knows nothing of discipling nations as nations. Although Christians can and should work for social good, Philemon reminds us of our primary method and mandate.

---

[25]E.g., Eph 6:5–9; Col 3:22–4:1; 1 Tim 6:1–2; Tit 2:9; 1 Pet 2:18. If a slave comes to Christ he is not to make his primary aspiration escape from slavery, but rather serve Christ where he is (1 Cor 7:21–23). One reason for this is that slaves and free are equal in Christ (1 Cor 12:13; Gal 3:28; Col 3:11).

## Appendix: Chiastic Arrangement of Philemon[26]

A 1–3 Epistolary. { a 1, 2 Names of those with Philemon.<br>b 3 Benediction.

B 4–7 Prayers of Paul for Philemon. Philemon's hospitality.

C 8 Authority.

D 9, 10- Supplication.

E -10 Onesimus, a convert of Paul's.

F 11, 12- Wrong done by Onesimus. Amends made by Paul.

G -12 To receive Onesimus the same as receiving Paul.

H 13, 14 Paul and Philemon.

I 15 Onesimus.

*I* 16- Onesimus.

*H* -16 Paul and Philemon.

*G* 17 To receive Onesimus the same as receiving Paul.

*F* 18, 19- Wrong done by Onesimus. Amends made by Paul.

*E* -19 Philemon a convert of Paul's.

*D* 20 Supplication.

*C* 21 Authority.

*B* 22 Philemon's hospitality. Prayers of Philemon for Paul.

*A* 23–25 Epistolary. { *a* 23, 24 Names of those with Paul.<br>*b* 25 Benediction.

---

[26]Adapted from E. W. Bullinger, *Figures of Speech Used in the Bible Explained and Illustrated* (London: Messrs. Eyre and Spottiswoode, 1898; reprint ed., Grand Rapids: Baker, 1968), 379.

សំណុំទឹកឃ្មុំ ២/១ (មករា ២០០១)៖ ៥៦-៧៦



# ការណែនាំឲ្យស្គាល់ពីលក្ខណៈគណ្ឌគម្ពីរភីលេម៉ូន

លោក រ៉ាស់ បាវើស៍

## ប្រវត្តិ

គ្មានសំបុត្រលោកប៉ូលណាមួយ ដែលទទួលការយកចិត្តទុកដាក់តិចជាងសំបុត្រភីលេម៉ូនទេ ។ ទន្ទឹមនឹងនោះ នៅតែគ្មានសំបុត្រណាមួយដែលពន្យល់ពីដំណឹងល្អច្បាស់លាស់ជាងនេះនោះឡើយ ។

លោកប៉ូលសរសេរសំបុត្រភីលេម៉ូនគឺផ្ញើទៅកាន់បុគ្គលផ្ទាល់ខ្លួន មិនដូចសំបុត្ររ៉ូម រហូតដល់សំបុត្រថែស្សាឡូនិចនោះទេ ។ សំបុត្រនេះផ្ដោតលើរឿងរ៉ាវផ្ទាល់ខ្លួន ជាជាងពួកជំនុំ ដែលមិនដូចជាសំបុត្រធីម៉ូថេ និងសំបុត្រទីតុសទេ ។ គឺជាសំបុត្រយ៉ាងខ្លីមួយ ក្នុងចំណោមសំបុត្រដ៏វែងៗទាំងឡាយរបស់ប៉ូល ។ អ៊ីចឹងហើយទើបសំបុត្រនេះមានលក្ខណៈពិសេស ។

គម្ពីរភីលេម៉ូន គឺជាសំបុត្រមួយនៃសំបុត្រចេញពីក្នុងគុករបស់ប៉ូលជាមួយនឹងសំបុត្រផ្ញើទៅក្រុងអេភេសូ ភីលីព និង កូល៉ុស[១] ។ ក្នុងចំណោមសំបុត្រទាំង៤នេះ កូល៉ុសនិងភីលេម៉ូនមានលក្ខណៈពិសេសក្នុងទំនាក់ទំនងជិតស្និតនឹងគ្នា[២]

---

[១] *មើលអេភេសូ ៣:១, ៤:១, ៦:២០; ភីលីព ១:១៣-១៤; កូល៉ុស ៤:១០; ភីលេម៉ូន ១:២៣*

[២] *មើលខយោងចំពោះ អេបា៉ ប្រាស ក្នុងកូល៉ុស ១:៧, ៤:១២ និង ភីលេម៉ូន ២៣ ។ ចំពោះអើឃីព ក្នុងកូល៉ុស ៤:១៧ និង ភីលេម៉ូន២ ចំពោះលោកលូកា*

ការជាប់គុកគឺប្រហែលជាការជាប់ឃុំនៅក្នុងផ្ទះរបស់ ប៉ូល ដែលបាន ពិពណ៌នាក្នុងគម្ពីរកិច្ចការជំពូក ២៨ ដូច្នេះការកំណត់កាលបរិច្ឆេទលើការ សរសេរសំបុត្រទាំងនេះ គឺនៅក្នុងអំឡុងគ.សឆ្នាំ ៦០-៦១ ។ នេះគឺជាការ ជាប់គុកលើកដំបូង មុនការជាប់គុកមួយ ដែលបានប្រាប់ឲ្យដឹងកាលពី ៦ ឆ្នាំក្រោយមក ក្នុងគម្ពីរ ២ធីម៉ូថេ[៣] ។ ក្នុងសំបុត្រដំបូងគេ លោកប៉ូលបាន សង្ឃឹមថា នឹងត្រូវបានគេដោះលែងយ៉ាងជាក់លាក់ ប៉ុន្តែក្នុងធីម៉ូថេទី២ លោកសាវ័កបានដឹងថា ការស្លាប់របស់គាត់កាន់តែជិតមកដល់ ហើយ (៤:៦) ពេលនេះគាត់មិននៅក្រោមការជាប់ឃុំ នៅក្នុងផ្ទះដ៏សុខស្រួល ទៀតទេ ប៉ុន្តែបានជាប់ច្រវ៉ាក់ (២:៩) គឺជាប់ក្នុងគុកក្រោមដីដ៏ត្រជាក់ (៤:១៣) ។ ការជាប់គុករបស់ប៉ូលបានសរសេរប្រាប់នៅក្នុងធីម៉ូថេទី២ ទោះជាយ៉ាងណាក៏មិនធ្វើឲ្យយើងខ្វល់ខ្វាយប៉ុន្មានទេនៅទីនេះ ។ នៅក្នុង អំឡុងពេលនៃការឃុំឃាំងនៅក្នុងផ្ទះលើកដំបូងរបស់គាត់ នៅក្នុងគម្ពីរ កិច្ចការជំពូក២៨ លោកសាវ័កពិតជាបានជួបជាមួយនឹងទាសករម្នាក់ដែល លួចរត់ចេញពីម្ចាស់ឈ្មោះថា អូនេស៊ីម ហើយបាននាំគាត់ឲ្យមានជំនឿ ក្នុងព្រះគ្រីស្ទ (មើលភីលេម៉ូន ១០) ។ ប្រហែលជា អូនេស៊ីម បានលួចរបស់អ្វីពីម្ចាស់ខ្លួនពិតមែន ហើយក៏បានរត់ចេញទៅ (ភីលេម៉ូន ១៨) ។ ប៉ុន្តែបើសិនជាគាត់មិនបានធ្វើវិញ គឺគាត់នៅតែជំពាក់បំណុល ចៅហ្វាយរបស់គាត់ភីលេម៉ូនដដែល ព្រោះថាការងារដែលត្រូវបំរើចៅ ហ្វាយនោះ គាត់ត្រូវសងវិញនូវគ្រប់ពេល ដែលគាត់បានរត់គេចមក

---

*និង ដេម៉ាស ក្នុងកូល៉ុស ៤:១៤ និង ភីលីព ២៤ និង ចំពោះម៉ាកុស និង អារីស្តាក ក្នុងកូល៉ុស ៤:១០ និង ភីលេម៉ូន ២៤ ។ អូនេស៊ីម - ទាសករដែលគឺ ជាប្រធានបទនៃសំបុត្រទៅភីលេម៉ូន - គឺជាម្នាក់ដែលកាន់សំបុត្រទាំងពីរ កូល៉ុស (៤:៩) និង ភីលេម៉ូន (១២) ។ សំបុត្រទាំងពីរនេះត្រូវបានសរសេរ ឡើងយ៉ាងច្បាស់លាស់នឹងបានបញ្ជូនទៅក្នុងពេលដូចគ្នា ។*

*[៣] មើល ១:១៦-១៧, ២:៩, ៤:៦-៨, ១៣ ។*

នោះ ។ ក្នុងសតវត្សទី១ ពួកទាសកររ៉ូម៉ាំងត្រូវបានរាប់ថាជាទ្រព្យសម្បត្តិនៃចៅហ្វាយរបស់ខ្លួន ដែលម្ចាស់មានសិទ្ធិនឹងប្រហារជីវិតទាសករនោះដោយគ្មានជាប់ទោសឧក្រិដ្ឋអ្វីឡើយ ។ ទោះជាយ៉ាងណាការត្រឹមត្រូវសំរាប់អូនេសិម ដែលជាគ្រីស្ទបរិស័ទថ្មីម្នាក់ត្រូវធ្វើនោះគឺត្រូវត្រឡប់ទៅឯចៅហ្វាយរបស់ខ្លួនវិញ ហើយថ្វីបើសេចក្តីស្លាប់គំរាមកំហែងរហូតដល់ត្រូវព្យួរកគាត់ក៏ដោយ ។ ដូច្នេះលោកប៉ូលបានសរសេរសំបុត្រខ្លីក្នុងព្រះគម្ពីររបស់យើងទៅកាន់លោក ភីលេម៉ូនដើម្បីអង្វរករសុំឲ្យគាត់ទទួលនិងអត់ទោសដល់ទាសកររបស់ខ្លួន ។

## ទិធានសម្រាយសង្ខេប

**លោកប៉ូលជំរាបសួរអ្នកអានរបស់គាត់** (១-៣) លោកប៉ូលកំពុងធ្វើការសុំអង្វរករមួយនៅក្នុងសំបុត្រនេះ ដូច្នេះគាត់មិនចាប់ផ្តើមដោយប្រើមុខងារដែលអាងខ្លួនជា "សាវ័ក" នោះឡើយ ។ ប្រាកដណាស់ហើយ គាត់គឺជាសាវ័កម្នាក់ ។ ហើយគាត់មិនចាំបាច់ខ្វល់ចិត្តអំពីការប្រាប់ខ្លួនថាគាត់ជាសាវ័កបែបហ្នឹង ហើយនិងពោលអះអាង ពីអំណាចដែលព្រះគ្រីស្ទបានប្រទានឲ្យនៅពេលណាដែលចាំបាច់ឡើយ[៤] ប៉ុន្តែពីព្រោះក្នុងករណីបច្ចុប្បន្នគាត់នឹងសុំដល់ចិត្តរបស់ភីលេម៉ូន គាត់ដាក់អំណាចរបស់គាត់នៅមួយចំហៀងសិន ។ គាត់ពោលអំពីខ្លួនគាត់ថាជា "អ្នកទោស" ដែលទំនងដូចជាសុំឲ្យមានការអាណិតអាសូរពី ភីលេម៉ូន ចំពោះសំណូមពររបស់គាត់ ។

---

*[៤] លោកប៉ូលប្រើឈ្មោះ "សាវ័ក" ក្នុងការជំរាបសួរនៃគ្រប់ទាំងសំបុត្ររបស់គាត់ក្នុងសញ្ញាថ្មីទាំងអស់ លើកលែងតែសំបុត្រ ភីលេម៉ូន ថែស្សាឡូនិចកីលីព ។ របៀបសរសេររបស់គាត់ គឺមិនលន់តួទោស ដែលធ្វើឲ្យស្រគៀត្រចៀក តាមរយៈ សំបុត្រទៅ កាឡាទី និង ការសម្គុតប្រើអំណាចក្នុង កូរិនថូសទី២ ១៣:១០ ។*

សំបុត្រសរសេរទៅកាន់លោក ភីលេម៉ូន (ជាអ្នកជឿនៅក្រុងកូល៉ុសម្នាក់ ហើយជាម្ចាស់ទាសករ) ទៅកាន់ អេផាស (ប្រហែលជាប្រពន្ធរបស់លោក ភីលេម៉ូន) ផ្ញើទៅកាន់ អើឃីព (ដែលប៉ូលហៅថា "មិត្តរួមអាវុធរបស់គាត់ ក្នុងការងារជាទាហាន..."របស់គាត់)[៥] និងទៅកាន់ពួកជំនុំ ដែលបានប្រជុំនៅផ្ទះរបស់ភីលេម៉ូន ។

**លោកប៉ូលសំដែងការអរគុណ និង អធិស្ឋានសំរាប់អ្នកអានរបស់គាត់** (៤-៧) ដើម្បីធ្វើឲ្យមានការរីករាយ លោកសាវ័កបានស្គាល់នូវភាពខុសគ្នា រវាងការសរសើរពិតប្រាកដ និង ការបញ្ជោរ ។

គាត់មិនលើករឿងថ្មី[៦] តែគាត់ក៏មិនចេញស្តីរឿងកន្លងមក ដែលធ្វើឲ្យគេខ្មាស់ដែរ[៧] យី! គួរឲ្យមានការលើកទឹកចិត្តមែនទែន ដែលអ្នកជួយលើកទឹកចិត្តដ៏ស្មោះត្រង់ ដែលចេះអរគុណដល់ព្រះជាម្ចាស់ ចំពោះការប្រកប ជំនឿ និង ការបំរើរបស់ខ្លួន ! សំបុត្រនេះបង្ហាញពីការរៀបចំចិត្ត ដើម្បីទទួលនូវការប្រឹក្សាផ្តល់យោបល់ និងពិចារណាមើល លើឱកាសថ្មីៗជាច្រើន ។ ការសរសើររបស់ប៉ូលក្នុងខទាំងនេះគឺមានសារៈសំខាន់គ្រប់គ្រាន់ល្មមគួរឲ្យកក់ក្តៅ និងជាលក្ខណៈផ្ទាល់ខ្លួន ប៉ុន្តែមិន

---

*(៥) ក្នុងកូល៉ុស ៤:១៧ ប៉ូលទទូចឲ្យ អើឃីព ដើម្បី "បំពេញការងារ (ដែលគាត់បាន) ទទួលក្នុងព្រះអម្ចាស់"*

*(៦) ថែស្សាឡូនិច ២:៥*

*(៧) លោកប៉ូលចាប់ផ្តើមសំបុត្ររបស់គាត់ ដោយការអរគុណសំរាប់អ្នកទទួលឬយ៉ាងហោចណាស់បូកបញ្ចូល ទាំងការសរសើរក្នុងកន្លែងណាមួយនៅក្នុងសំបុត្រនោះ ។ គាត់ធ្វើរបៀបនេះទោះទាំងសំរាប់ពួកជំនុំដែលគាត់មិនដែលជួប (ពួកជំនុំរ៉ូម ពួកជំនុំកូល៉ុស) ហើយអស់អ្នកដែលព័ទ្ធជុំវិញដោយបញ្ហា (កូរិនថូស១) ។ គំរូនេះបណ្តាលឲ្យសរសេរសំបុត្រទៅកាឡាទី-ដែលគឺស្ថិតនៅក្នុងគ្រោះថ្នាក់នៃការរត់ចោលដំណឹងល្អដោយព្រោះច្បាប់-ឈរក្នុងភាពផ្ទុយគ្នា ។*

សរសើរហួសហេតុពេកដែលបានធ្វើឲ្យផែនការលេចឡើង ឬអាចជាការរៀបចំដោយល្បិចដើរខ្សែលើនោះឡើយ ។

លោក ភីលេម៉ូន ស្ថិតក្នុងសេចក្ដីអធិស្ឋានរបស់លោកប៉ូលជានិច្ច គឺថាៈទី១ អរគុណលោកសាវ័កបានឮពីជំនឿរបស់ ភីលេម៉ូនក្នុងព្រះគ្រីស្ទ និងសេចក្ដីស្រឡាញ់ដល់ពួកបរិសុទ្ធ[៨]ហើយទី២ គាត់សុំភីលេម៉ូននូវការដែលគាត់កាន់យ៉ាងហ្មត់ចត់[៩] គ្រប់ទាំងការល្អដែលយើងមានក្នុងព្រះគ្រីស្ទ ដូច្នេះដែលការចែកចាយនៃជំនឿរបស់គាត់ អាចក្លាយជាមានប្រសិទ្ធិភាព ។ ចំណេះដឹងរបស់យើងពីយើងជានរណាក្នុងព្រះគ្រីស្ទ ត្រូវកើតឡើងមុន ហើយគឺជាមូលដ្ឋានសំខាន់ សំរាប់ការមានផលផ្លែរបស់យើងយ៉ាងពេញលេញ ។[១១]

លោកបញ្ចប់នៃការសរសើររបស់គាត់ ចំពោះលោក ភីលេម៉ូន ដោយប្រាប់ ភីលេម៉ូន ពីសេចក្ដីអំណរ និង ការលើកទឹកចិត្តដែលគាត់បាននាំមកមិត្តចាស់របស់គាត់ និង ដោយហៅភីលេម៉ូនថា "ប្អូន" និង ដោយសង្កេតឃើញថា ភីលេម៉ូនបានជួយបង្កើនជំនឿដល់ពួកអ្នកជឿ ។

---

*[៨] តាមន័យរបស់ពាក្យ "សេចក្ដីស្រឡាញ់ និង ជំនឿដែលអ្នកមានក្នុងព្រះអម្ចាស់យេស៊ូវ និង ចំពោះពួកបរិសុទ្ធទាំងអស់គ្នា" ការបកប្រែខ្លះ បកស្រាយខនេះដូចជាភាពខ្វែងគ្នា ឬ ជាការរៀបរៀប* **ab:ba** *។ ដូច្នេះសេចក្ដី ស្រឡាញ់" គឺបានបង្ហាញចំពោះ "ពួកបរិសុទ្ធ" និង ជំនឿ "គឺដាក់" ព្រះអម្ចាស់យេស៊ូវ " ភាពខ្វែងគ្នាគឺជារឿយៗជាចិត្តបំណងខាងអក្សរសាស្ត្រមួយក្នុងបទគម្ពីរ ។ តាមការពិត សំបុត្រទាំងមូលទៅកាន់ លោកភីលេម៉ូន ប្រហែលជាត្រូវមើលជា . . . មើលសេចក្ដីបន្ថែម ។*

*[៩] ភាពពិតប្រាកដ លោកភីលេម៉ូនស្គាល់ការអ្វីដែលល្អ ដែលយើងមានក្នុងព្រះគ្រីស្ទ ហើយលោកប៉ូលអធិស្ឋានថាគាត់នឹងយល់អំពីការទាំងនេះ ក្នុងមធ្យោបាយបានកាន់តែពោរពេញ និង កាន់តែជ្រៅជាង ។*

*(១១) មើលឧទាហរណ៍ កូល៉ុស ១:៩-១២*

លោកប៉ូលសុំឲ្យភីលេម៉ូនទទួល និង អត់ទោសដល់អូនេស៊ីម (៨-២២) សាវ័កនឹងមិនប្រើអំណាចរបស់គាត់ ដើម្បីបង្ខំចិត្តរបស់ភីលេម៉ូនទេ ។ តែបែរជាសុំដល់ម្ចាស់ទាសករលើមូលដ្ឋាន (១)សេចក្តីស្រឡាញ់ (២)វ័យចាស់របស់គាត់ (៣) ឋានៈគួរឲ្យអាណិត ក្នុងនាមជាអ្នកទោសម្នាក់ ដោយព្រោះព្រះគ្រីស្ទ (៤)ទំនាក់ទំនងរបស់គាត់ចំពោះអូនេស៊ីមជា "ឪពុក" និង (៥)ចំណងចិត្តដ៏កក់ក្តៅចំពោះអូនេស៊ីម ("ជាដួងចិត្តនៃខ្ញុំ" ១១២) ។ សំណូមពររបស់គាត់គឺមោះមុតណាស់ ។ ទាសករដែលលួចរត់ចេញទៅនោះគ្មានការការពារណាមួយថាស្របច្បាប់នោះទេ ។ នៅពេលដែលគេរកឃើញទាសករដែលបានរត់ទៅនោះ គេនឹងត្រូវតែទទួលនូវការវាយដំបង្ខំឲ្យធ្វើការឥតត្រាប្រណី ដែលជាហេតុបណ្តាលឲ្យជីវិតរស់នៅកាន់តែរួញខ្លី ។ ដោយស្នើឲ្យលោកអូនេស៊ីមរួចពីទណ្ឌកម្មដែលលោកប៉ូលកំពុងតែសុំដល់លោកភីលេម៉ូន ឲ្យប្រព្រឹត្តល្មើសប្រពៃណីរបស់ពួករ៉ូម៉ាំង ។ ជំហានបែបនេះអាចផ្តល់នូវសេចក្តីថ្លៃថ្នូរដល់ទាសករ ដែលមិនធ្លាប់មាននៅមនុស្សជាតិនៅសម័យនោះ និងអាចជំរុញទស្សនៈសេដ្ឋកិច្ច និងឥទ្ធិពលសង្គមដែលគេអាចទទួលយកបាន ។ យ៉ាងណាក៏ដោយ នេះគឺជាអ្វី ដែលលោកប៉ូលស្នើសុំយ៉ាងជាក់លាក់ ។

គាត់ទទូចសុំ "ចំពោះកូនរបស់ខ្ញុំ អូនេស៊ីម" ដែលបានក្លាយជាកូនរបស់ខ្ញុំអំឡុងពេលដែលខ្ញុំជាប់ច្រវាក់ " "អូនេស៊ីមគឺមានន័យថា "មានប្រយោជន៍" ឬ "ដែលឲ្យគុណប្រយោជន៍" គឺជាឈ្មោះមួយទូទៅសំរាប់ទាសករ ។ "មានប្រយោជន៍" គឺកាលពីមុនបែរជា "គ្មានប្រយោជន៍" នៅពេលនេះ ប៉ុន្តែឥឡូវនេះគាត់ជាគ្រីស្ទបរិស័ទម្នាក់បានត្រឡប់ក្លាយជា "មានប្រយោជន៍" ។ នេះគឺជាការគួរឲ្យអស់សំណើចចំពោះការលេងពាក្យនេះគឺត្រូវបានរៀបចំឡើង ដើម្បីឲ្យបន្ទន់ចិត្តដល់លោកភីលេម៉ូន ដែលកំពុងអាក់អន់ចិត្តឲ្យបានពួពីសំណើចរបស់លោកប៉ូល ។

អ្នកជាប់គុក ដែលចង់រក្សាទុក លោកអូនេស៊ីម ដែលឥឡូវនេះមានប្រយោជន៍ឲ្យមកជួយគាត់វិញ ប៉ុន្តែដើម្បីឲ្យគ្រប់ទាំងការល្អ ដែលភីលេម៉ូន គប្បីធ្វើដោយពេញចិត្ត នោះត្រូវធ្វើដោយមានសេរីភាពជាជាងដោយមានការបង្ខិតបង្ខំ ។ ដូច្នេះលោកប៉ូលបញ្ជូនគាត់ ឲ្យត្រឡប់មកវិញ ។ ខ១៥ និង ១៦បានបង្ហាញពីពាក្យផ្ទុយទាំងគូៗ ដែលគេយកមកបង្រួមគ្នាដូចជាពាក្យថា បានបែកទៅ ឥឡូវវិលមកវិញ មានពេលតិចតួចតែឥឡូវមានពេលធ្វើការល្អ មិនមែនមកវិញជាទាសករទៀតទេ តែវិលមកវិញក្នុងឋានៈជាបងប្អូនស្ងួនភ្ងាវិញ ។ ការបកស្រាយផ្ទុយគ្នាទាំងនេះ ដែលជាឱកាសដ៏ល្អបាននាំមកឲ្យគេបានដឹង នៅពេលដែលមនុស្សជឿដំណឹងល្អ ។

បន្ទាប់ពីការរៀបចំចិត្តរបស់ ភីលេម៉ូន ដោយប្រុងប្រយ័ត្នរួចមក លោកប៉ូលទីបំផុតបញ្ចេញសម្លេងសំណូមពរក្នុង ខ១៧ ។ គ្រប់ទាំងអស់បានធ្វើរួចហើយ មុនបង្កើតឆាកយ៉ាងសាមញ្ញសំរាប់បរិយាកាសនៃការទទួលសុំ ។ លោកប៉ូលមានប្រសាសន៍ថា "បើអ្នករាប់ ខ្ញុំទុកជាគូកន[១២] នោះចូរទទួលស្វាគមន៍គាត់ទុកដូចជាទទួលខ្ញុំចុះ ។ ពីព្រោះតែភាពខុសគ្នាយ៉ាងធំធេងរវាងឋានៈជាទាសករ និងម្ចាស់របស់ពួកគេ ដូច្នេះហើយ ដែលប្រពៃណីបានដាក់បន្ទុកដល់ម្ចាស់ទាសករ ធ្វើឲ្យឈឺចាប់ ថាតើគួរគប្បីប្រព្រឹត្តយ៉ាងដូចម្តេច ចំពោះការលួចរត់ចេញទៅរបស់ទាសករនោះ

---

*[១២] ពាក្យនេះមានន័យថា "សហជីវិន គូកន អ្នកមានចំណែក គឺជាម្នាក់ដែលរួមចំណែកជាមួយអ្នកដទៃក្នុងការទទួលភារៈខ្វះ ឬ រឿងរ៉ាវស្តីអំពីការចូលរួម" គំនិតនៃការទទួលភារៈជាទូទៅនៅពេលដែលមនុស្សរួមគ្នាវិនិយោគ និង ចូលរួមចំណែក និង ដោយដាក់ឫសនៃពាក្យនេះ ហើយឫសគល់របស់ពាក្យនេះ គឺទៅឆ្ងាយហួសពីន័យលាក់កំបាំងរបស់សង្គម ដែលពាក្យជាប់ទាក់ទងគឺ "ប្រិយសម្ព័ន្ធ" ប្រើជាញឹកញាប់ ។ ប៉ូល និង ភីលេម៉ូនគឺជាគូកន ក្នុងជំនឿ និង ការផ្សព្វផ្សាយដំណឹងល្អនៃព្រះគ្រីស្ទ ។*

សំណូមពររបស់លោកប៉ូលគឺជាការធ្វើឲ្យស្រទន់ឡាំងកាំង ។ ដោយការផ្ដល់ឲ្យមានលក្ខណៈបែបដូចជាមនុស្សធម៌ និង ជាសេចក្ដីថ្លៃថ្នូរដល់ទាសករដែលប្រែចិត្ត នេះជាការដាក់សំពៀងនៅនឹងមុខ និងបានថ្កោលទោសដល់ការឲ្យតម្លៃមនុស្សជាតិនាសម័យនោះ ដែលខ្វះនូវភាពមនុស្សធម៌ ។ ជំនឿគ្រីស្ទបរិស័ទដែលជាញើកញាប់គឺការធ្វើការដូច្នោះឯង ។

ប៉ុន្តែតើបំណុលរបស់លោកនឹងទៅជាយ៉ាងណាវិញ? ការនោះគឺត្រូវបានដោះស្រាយឲ្យរួចផងដែរ គឺលោកប៉ូលជាអ្នកចេញសងនូវការខូចខាតទាំងអស់នោះ ។ អីចឹងមកដល់ពេលនេះសេចក្ដីថ្លែងការណ៍របស់កូនបំណុលដែលបានកំណត់តាមផ្លូវច្បាប់ ហើយលោកសាវ័កប៉ូលសរសេរដោយផ្ទាល់ថា នឹងចេញថ្លៃសងវិញ ។ ប៉ុន្តែតាមការពិត! ដោយហេតុថាលោកប៉ូលបាននាំគាត់ឲ្យមានជំនឿក្នុងព្រះគ្រីស្ទមក គឺលោក ភីលេម៉ូនបានជំពាក់បំណុលដល់លោកសាវ័កគឺខ្លួនរបស់គាត់នោះឯង ។ តាមរយៈដំណឹងល្អ ដែលលោកប៉ូលបាននាំមក បំណុលនៃអំពើបាបរបស់ លោកភីលេម៉ូន និង ការផ្ដន្ទាទោសត្រូវបានចេញសង ដូច្នោះហើយ តើគាត់អាចទាញយកពីលោកសាវ័កនូវប្រាក់បំណុលនេះបានដូចម្ដេច?

មែនហើយលោកប៉ូលកំពុងសុំឲ្យ ភីលេម៉ូនលើកលែងកំហុសដ៏ធំរបស់អូនេស៊ីម និង ស្នើឲ្យបញ្ឈប់គ្រប់ការសងបំណុលណាមួយនោះ ។

គាត់បានសម្រេចនូវសំណើដ៏ពិបាកនេះ ។ ភីលេម៉ូនថ្លឹងពាក្យរបស់លោក ប៉ូល ។ ខណៈដែលគាត់ឈរ មានសំបុត្រនៅក្នុងដៃ បាវបំរើបានលួចរត់ទៅកំពុងក្រាបជិតជើងរបស់គាត់ ហើយលោកប៉ូលជំរុញគាត់ឲ្យឈានវំលងខ្សែបន្ទាត់: "អើ ប្អូនអើយសូមឲ្យខ្ញុំបានផលនេះអំពីអ្នកក្នុងព្រះអម្ចាស់" ពាក្យបានបកប្រែថា "រីករាយនឹងបានផលប្រយោជន៍" គឺចេញមកពីកំណើតពាក្យដូចគ្នានឹងឈ្មោះ អូនេស៊ីម ហើយបន្តប្រើឈ្មោះរបស់ទាសករនោះតាមការប្រសប់ប៉ិនលេងពាក្យរបស់ ប៉ូល ។ លើសពីនោះ ភីលេម៉ូនបានធ្វើឲ្យចិត្តនៃពួកបរិសុទ្ធ បានស្រស់បស់ឡើង (ខ៧)

តើគាត់ អាចខកខានធ្វើតាមសំណើរបស់មនុស្សម្នាក់ ដែលបាននាំគាត់ទៅឯព្រះគ្រីស្ទបានយ៉ាងដូចម្ដេច? ខ២០? ដោយឆ្លើះគាត់ បន្ថែមទៀត លោក ប៉ូល សំដែងនូវការទុកចិត្តរបស់គាត់ថា ភីលេម៉ូននឹង ធ្វើមិនត្រឹមតែអ្វី ដែលគាត់បានសុំប៉ុណ្ណោះទេ ប៉ុន្តែនឹងធ្វើលើសអំពីនេះ ទៅទៀត[១៤] បើសិនភីលេម៉ូននៅតែស្ទាក់ស្ទើរក្នុងការធ្វើតាមនោះ គាត់នឹងត្រូវមានសេចក្ដីពន្យល់ផ្ទាល់ខ្លួនទៅលោក ប៉ូល ពីមូលហេតុ ដែល គាត់មិនបានធ្វើតាម ដោយហេតុថាអ្នកទោសម្នាក់នេះសង្ឃឹមថានឹងមកសួរសុខទុក្ខគាត់ក្នុងពេលឆាប់ៗ ។

តើភីលេម៉ូនបានអត់ទោសឲ្យអូនេស៊ីម ដូចដែលលោកប៉ូលសុំដែរឬទេ? យើងមិនដឹងទេ ។ ប៉ុន្តែការពិតនោះគឺថា សំបុត្រនេះត្រូវបានបញ្ចូលទៅក្នុងព្រះគម្ពីរ ផ្ដល់ជាយោបល់ថាគាត់បានធ្វើតាម ។ ដោយគួរឲ្យចាប់អារម្មណ៍ បីបួនទសវត្សក្រោយមក លោកអ៊ីហ្គ័ណាទាស (Ignatius) និយាយយោងយ៉ាងកក់ក្ដៅចំពោះបូជាចារ្យនៅជិតក្រុងអេភេសូ[១៥] ថា "... អូនេស៊ីម គឺមនុស្សម្នាក់ដែលមានសេចក្ដីស្រឡាញ់ ដ៏ធំអស្ចារ្យ ហើយដែលជាបូជាចារ្យរបស់អ្នក ដែលខ្ញុំអធិស្ឋានឲ្យ អ្នកដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទឲ្យមានសេចក្ដីស្រឡាញ់ ហើយពីអធិស្ឋានសុំឲ្យអ្នកនឹងស្វែងរកសេចក្ដីស្រឡាញ់ឲ្យដូចជាគាត់ដែរ ។ សូមឲ្យព្រះបានប្រកបដោយព្រះពរ ដែលទ្រង់ហើយបានប្រទានពរដល់អ្នក ដែលគឺខ្លួនរបស់អ្នកផ្ទាល់ មានភាពឧត្ដុង្គឧត្ដមម្ល៉េះ ដោយបានទទួលបូជាចារ្យដ៏ឧត្ដមនេះ[១៦]" ។ នេះជាការគួរឲ្យចាប់អារម្មណ៍ចំពោះការពិសេសនេះ

---

[១៤] *ប្រហែលបានមានសង្ឃឹមថា ភីលេម៉ូនអាចដោះចំណងអូនេស៊ីម ប៉ុន្តែមិនដែលត្រូវបានសុំឲ្យគាត់ធ្វើការនេះទេ ។*

[១៥] *អេភេសូគឺប្រហែល ១៦០ គីឡូម៉ែត្រ ខាងទិសពាយព្យនៃកូឡុសក្នុងអាណា ខេត្តរ៉ូមនៃអាស៊ី ។*

(១៦) *អ៊ីហ្គ័ណាទាស* (Ignatius) *ចំពោះអេភេសូ ជំពូក១*

ដែលទាសករម្នាក់បានទទួលនូវការអត់ ទោសបានបន្តបំរើពួកជំនុំក្នុង មធ្យោបាយដ៏មានតម្លៃ និង ដ៏មានសារៈសំខាន់នោះ ។

**លោកប៉ូលជូយបន្ថការជំរាបសួររបស់អ្នកផ្សេងទៀតមកឲ្យយើង** (២៣-២៥) លោក ប៉ូលបញ្ចប់សំបុត្ររបស់គាត់ដោយលើកយកពាក្យជំរាបសួរអ្នកជឿដទៃទៀតមកបញ្ចូប់ ។ អេប្រ៉ាប្រាស បានផ្សាយដំណឹងល្អដល់កូល៉ុស និង បានបន្តអធិស្ឋានសំរាប់ភាពពេញវ័យ របស់ពួកជំនុំ ។[១៧] លោកម៉ាកុស ដែលលោកប៉ូលបានបដិសេធពីគ្រាដំបូង ដោយមិនរាប់ជាសមាជិក កាលពីដំណើរបេសកកម្មលើកទី២[១៨] តែម្តងនេះគេបាន ទុកគាត់ជាម្នាក់ នៃ "សហជីវិន" របស់លោកសាវ័ក ។ អើរីស្តាក គឺជាអ្នកថែស្សាឡូនិច ដែលត្រូវបានគេចាប់ខ្លួនក្នុងកុប្បកម្ម នៅឯក្រុងអេភេសូ ហើយដែលបានធ្វើជាគូកនរបស់លោក ប៉ូល ក្នុងដំណើររបស់គាត់ទៅកាន់ ក្រុងយេរ៉ូសាឡឹម និង រ៉ូម ។[១៩] ដាម៉ាស់ ថ្វីបើត្រូវគេហៅនៅទីនេះថាជាសហជីវិនរបស់លោកប៉ូល ក៏ពិតមែនតែគ្រាក្រោយមកបានរត់ចោលគាត់ ព្រោះតែការស្រឡាញ់លោកិយបច្ចុប្បន្ននេះ[២០] លោក លូកា គឺជាលោកគ្រូពេទ្យសាសន៍ដទៃ ដែលបាននិពន្ធគម្ពីរលូកា និង កិច្ចការ ។

---

*(១៧) កូល៉ុស ១:៧, ៤:១២-១៣*

*(១៨) កិច្ចការ ១៥:៣៦-៤១*

*(១៩) កិច្ចការ ១៩:២៨-២៩, ២០:៤, ២៧:២*

*(២០) ២ធីម៉ូថេ ៤:១០*

ការជួយគំនិតផ្នែក ទេវសាស្ត្រ និង ការអនុវត្តន៍ជាក់ស្តែង

ការបកស្រាយបំភ្លឺដំណឹងល្អ




ដូចដែលគំនូសតាងខាងលើ ពន្យល់ពីទំនាក់ទំនងរវាងប៉ូល និង ភីលេម៉ូន ជាដៃគូសមភាព និង មានការគោរពរាប់អានគ្នា ។ នៅម្ខាងទៀត ភីលេម៉ូន គឺជាម្ចាស់របស់អូនេស៊ីម និងជាចៅហ្វាយ ។ អូនេស៊ីម បានធ្វើខុស ចំពោះចៅហ្វាយរបស់ខ្លួន ដែលអាចធ្វើឲ្យគាត់ទទួលសងដល់សេចក្តីស្លាប់នៅក្នុងកណ្តាប់ដៃរបស់ចៅហ្វាយរបស់ខ្លួន ។




*អនុវត្តដំណើរក្នុងភាពអាចទទួលយកបាន*
*នៃការទូទាត់សង និង ការទូលអង្វរ ។*

ទោះជាយ៉ាងណាក៏ដោយ លោកប៉ូល បានឲ្យអូនេស៊ីម អង្វរសុំទោសភីលេម៉ូន ក្នុងនាមរបស់លោក ប៉ូល និង ចេញសងថ្លៃបំណុលរបស់អូនេស៊ីម ។ អូនេស៊ីមបន្ទាប់មកបានយកជីវិតរបស់គាត់ទៅដាក់ក្នុង

ដៃរបស់ចៅហ្វាយគាត់ ហើយនិងបានទុកចិត្តលើលោក ប៉ូល គឺថាការទូលអង្វរ របស់គាត់ ដែលអាចបង្ហាញភស្តុតាង ដែលគួរឲ្យទទួលចំពោះ ភីលេម៉ូន ហើយជីវិតរបស់គាត់នឹងបានទទួលការត្រាប្រណី ព្រមទាំងបានត្រឡប់ទៅឯចៅហ្វាយរបស់ខ្លួនវិញ ។




លោកប៉ូលបានស្នើថា សុំឲ្យលោកភីលេម៉ូនធ្វើការផ្លាស់ប្ដូរពីការដែលនឹងកើតឡើងតំណាលគ្នា ។ ដំបូង ឲ្យភីលេម៉ូនគិតបំណុល របស់អូនេស៊ីម ទៅលើបន្ទុករបស់លោក ប៉ូល : "បើសិនជាគាត់បានធ្វើអ្វីខុសឆ្គងនឹងអ្នក ឬ ជំពាក់អ្នក នោះត្រូវគិតពីលើខ្ញុំវិញ ។ ប៉ូលខ្ញុំសរសេរដោយដៃខ្លួនថា ខ្ញុំនឹងសងអ្នក" ទី២ ម្ចាស់ទាសករយកឋានៈរបស់ប៉ូល ហើយផ្ដល់ឋានៈនេះទៅឲ្យអូនេស៊ីម : ចូរទទួលគាត់ ដូចជាខ្លួនខ្ញុំចុះ" ទោះបីនៅក្នុងសំបុត្រ ដែលសំណើពីឋានៈនេះដាក់នៅចំពោះមុខម្ចាក់ដែលជាប់បំណុលក៏ដោយ ក៏វាដើរតាមការដោះស្រាយដោយសមហេតុផលក្នុងការដោះស្រាយបំណុលនោះដែរ ។

*ការផ្លាស់ប្ដូរបញ្ចាំងឲ្យឃើញការប្រោសលោះដែលអ្នកមានបាប រកឃើញក្នុងព្រះគ្រីស្ទ ។*




ទំនាក់ទំនងរវាងព្រះគ្រីស្ទ គឺជាភាពតែមួយដ៏ជ្រៅ និង ភាពជាដៃគូមួយ ។ ព្រះយេស៊ូអង្គទ្រង់ផ្ទាល់បានមានបន្ទូលពីការនេះ នៅពេលទ្រង់បានពោលអះអាង "ខ្ញុំនិងព្រះវរបិតាគឺតែមួយ (យ៉ូហាន ១០:៣០)" ។ ពីរគឺមិនដូចគ្នាសុទ្ធសាធទេ ប៉ុន្តែបានរួបរួមដោយសេចក្ដីស្និទ្ធស្នាល និង ដោយមិនអាចបំបែកគ្នាបាន ។ មូលដ្ឋានទំនាក់ទំនងរវាងព្រះ និង មនុស្សម្នាក់ៗ គឺថាអ្នកបង្កើត និង ចៅហ្វាយ ប៉ុន្តែតាំងពីគ្រប់ទាំងអស់នៅក្នុងអាដាមគឺជាអ្នកមានបាបមក ដោយនិស្ស័យ និង ដោយការជ្រើសរើសពួកគេឈរចំពោះទ្រង់ ដូចជាកូនបំណុល ដែលបានទទួលការគំរាមកំហែងដោយសេចក្ដីស្លាប់ដ៏អស់កល្ប ។

*ការផ្ដល់ឲ្យចំពោះការជួយសុំទោសឲ្យ និង ការសងបំណុល*




*អនុវត្តជំនឿក្នុងភាពអាចទទួលយកបាន នៃការសងថ្លៃ និង ការទទួលអង្វរ*

ចេញពីសេចក្តីមេត្តាករុណា ព្រះគ្រីស្ទជួយសុំទោសសំរាប់អ្នកមានបាបម្នាក់ៗ ។ មុនដំបូងថ្វាយចំពោះការសងបំណុលអំពើបាបនីមួយៗ គឺថាព្រះគ្រីស្ទបានមក "ដើម្បីប្រទានជីវិតរបស់ទ្រង់ទុកជាតម្លៃលោះមនុស្សជាច្រើន"[២១] ព្រះជាម្ចាស់បង្កើតទ្រង់ដោយគ្មានបាបសោះ ឲ្យត្រឡប់ជាមានបាបសំរាប់យើងវិញ" (២កូរិនថូស ៥:២១)

"ព្រះយេស៊ូ . . . បានរងទុក្ខដល់សុគត ដូច្នេះដោយសារព្រះគុណរបស់ព្រះជាម្ចាស់ នោះព្រះអង្គអាចភ្លក់សេចក្តីស្លាប់សំរាប់មនុស្សគ្រប់គ្នា (ហេព្រើ ២:៩)" ទ្រង់គឺត្រូវរបួសសំរាប់អំពើរំលងរបស់យើង ក៏ត្រូវបានគេវាយដំសំរាប់អំពើទុច្ចរិតរបស់យើង និង ជាទណ្ឌកម្មដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជាដោយសារស្នាមរំពាត់នៅលើទ្រង់ . . . ព្រះយេហូវ៉ាបានទម្លាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់" (អេសាយ៥៣:៥-៦) ។ ព្រះយេស៊ូវបានដូចជាសេចក្តីសង្គ្រោះ ដើម្បីរំដោះឲ្យរួចពីបំណុល[២២] ដោយបានសងថ្លៃបំណុលរបស់អ្នកមានបាប នោះទ្រង់បានប្រទានឲ្យនូវឋានៈរបស់ទ្រង់ផ្ទាល់ចំពោះព្រះភ័ក្ត្រព្រះវរបិតា "ដើម្បីឲ្យយើងរាល់គ្នាត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនៅក្នុងទ្រង់" (២កូរិនថូស ៥:២១) គឺដោយសារព្រះ នោះអ្នកនៅក្នុងព្រះគ្រីស្ទយេស៊ូវ ដែលបានក្លាយជាប្រាជ្ញាសំរាប់យើង ដែលមកពីព្រះ-នោះគឺសេចក្តីសុចរិតរបស់យើង

---

[២១] *ម៉ាកុស ១០:៤៥ ជាញឹកញាប់ត្រូវបានចាត់ទុកថាខសំខាន់សំរាប់ដំណឹងល្អនេះ ។ ពាក្យតម្លៃលោះមានន័យថាតម្លៃ ឬ មានន័យដោយ ការដោះលែងគឺធ្វើឡើងដែលអាចធ្វើទៅបាន ។*

[២២] *ការដោះលែង ដែលអាចធ្វើទៅបាន ។ ១ធីម៉ូថេ ២:៦ ប្រើបញ្ញត្តិ (ពាក្យ) ដែលជាប់ទាក់ទងគ្នា ។ ទាំងពីរនេះបញ្ជាក់ន័យពីការសងទូទាត់ ។ សូមមើលផងដែរ ១កូរិនថូស ៦:២០; ១ពេត្រុស ១:១៨ តទៅ ។ម៉ាថាយ ១៨:២១-២៧; លូកា ៧:៤០-៥០; ម៉ាថាយ ៦:១២*

សេចក្ដីបរិសុទ្ធ និង សេចក្ដីប្រោសលោះ" (១កូរិនថូស ១:៣០) យើងនៅក្នុង "ព្រះគ្រីស្ទ" ហើយបានអនុញ្ញាតឲ្យអធិស្ឋាន "ក្នុងព្រះនាមរបស់ព្រះយេស៊ូវ" អ្វីដែលបានតម្រូវដល់អ្នកមានបាបគឺថា អ្នកមានបាបនោះឯងមានជំនឿនៅក្នុងទំនាក់ទំនងរវាងព្រះគ្រីស្ទនិងព្រះវរបិតា ហើយនិងនៅក្នុងការសងថ្លៃ ដែលអាចទទួលយកបានដែលព្រះគ្រីស្ទបានធ្វើ ព្រមទាំងចូលទៅជិតព្រះវរបិតាក្នុងព្រះនាមព្រះយេស៊ូវ សំរាប់ការអត់ទោស ដែលបានសន្យា និងទំនាក់ទំនងថ្មីដូចជាកូនប្រុស ឬ កូនស្រីអ៊ីចឹង ។




នៅពេលជំនឿបែបនេះត្រូវបានអនុវត្ត នោះព្រះជាម្ចាស់ធ្វើការប្ដូរបំណុលរបស់អ្នកមានបាបទៅឲ្យព្រះគ្រីស្ទវិញ យ៉ាងពិនិត្យពិច័យ និងសេចក្ដីសុចរិត និង ភាពអាចទទួលយកបានរបស់ព្រះគ្រីស្ទឲ្យដល់ពួកអ្នកមានបាប ។

ប្រសិនបើលោក ភីលេម៉ូន បានស្ដាប់តាមសេចក្ដីសំណូមរបស់លោក ប៉ូល នោះការអត់ទោស និង ការព្រមទទួលយក អូនេស៊ីម អាចពន្យល់ពីដំណឹងល្អ ទៅដល់អ្នកដែលមកស្គាល់អំពីដំណឹងល្អ គឺនិងធ្វើឲ្យ ភីលេម៉ូន បង់ខាតអត់ "សិទ្ធិ" របស់គាត់ទាំងពីរ គឺទាំងការបាត់បង់ថវិកា និង បាត់បង់ឱកាសសំរាប់ការសងសឹកផ្ទាល់ខ្លួន ។ ប៉ុន្តែជីវិតអាចមានអស់កល្បបន្ទាប់ពីការផ្ដល់នូវការរស់នៅជាគំរូដ៏ រស់ពីរបៀបដែល

ព្រះយេស៊ូវប្រោសឲ្យជានូវទំនាក់ទំនងនេះ ។ ព្រះគម្ពីរ សញ្ញាថ្មីជារឿយៗ ជំរុញឲ្យអ្នកគ្រីស្ទាន "ធ្វើទង្វើ" របស់ដំណឹងល្អក្នុង របៀបដូចគ្នា ទៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃ[២៣] ។

*ការប៉ិនប្រសប់ ឬ ទេពកោសល្យ:* មានពួកអ្នកដែលជឿថា អំណាច និង តួនាទីផ្តល់ឲ្យពួកអ្នកដែលមាននូវសិទ្ធិក្នុងការអនុវត្តន៍ លើការវាយដំលើពួកគេដែល "ទន់ទាប" ។ នោះគឺជាបញ្ជារបស់ពួកគេ ហើយអ្នកដទៃត្រូវស្តាប់បង្គាប់ ។ អ្នកធំឡើងឋានៈកាន់តែខ្ពស់ សង្កត់សង្កិនអ្នកដទៃកាន់តែខ្លាំង ដោយការត្រួតត្រាតាមរយៈច្បាប់ ។ លោក ភីលេម៉ូន បដិសេធការសន្មត់បែបអ៊ីចឹង ។

លោក ប៉ូល ជាសាវ័កបានទទួលអំណាចដោយព្រះគ្រីស្ទ ដ៏មានព្រះជន្មរស់ ។ ប៉ុន្តែនៅទីនេះគាត់លះបង់ចោលសិទ្ធិអំណាចនោះ ដើម្បីទូលអង្វរមិត្តសម្លាញ់ចាស់ម្នាក់វិញ ។ គាត់នឹងមិនបង្ខំចិត្តរបស់លោក ភីលេម៉ូន ទេ ហើយគាត់បដិសេធក្នុងការបញ្ជាលោក ភីលេម៉ូន ។ គាត់នឹងធ្វើការទទូចសុំដោយពឹងផ្អែកលើលក្ខណៈនៃដំណឹងល្អ និង លើទំនាក់ទំនង ដែលពួកគេពេញចិត្ត ។ ក្នុងមធ្យោបាយនេះ គ្រប់ទាំងការល្អដែលភីលេម៉ូនធ្វើ នឹងជាការជ្រើសរើសរបស់គាត់ផ្ទាល់ នោះហើយដែលជាការគួរឲ្យសរសើរ ។ លោក ភីលេម៉ូន នឹងទទួលកិត្តិយសមិនមែនលោក ប៉ូល ទេ ។ ក្នុងពេលជាមួយគ្នាលោក ប៉ូល បានដាក់ខ្លួនគាត់នៅក្នុងស្ថានភាពគ្រោះថ្នាក់: លោក ភីលេម៉ូន អាចមិនអើពើនូវសំណូមពររបស់គាត់ ហើយទុកឲ្យគាត់គ្មានអានុភាព ដើម្បីទប់ទល់រឿងរ៉ាវនេះ ។ ពេលនោះ ភាពជាអ្នកដឹកនាំរបស់ ប៉ូល អាចត្រូវបានខូចខាតកិត្តិយស ។ ប៉ុន្តែគាត់ស្ម័គ្រធ្វើខ្លួនគាត់បង្ហាញឲ្យឃើញថាខ្សោយ ដើម្បីទុកឲ្យលោក

---

[២៣] *មើលឧទាហរណ៍ អេភេសូ ៤:២៣; ៥:២២,២៥*

ភីលេម៉ូន ដែលមានអំពើពេញដោយចិត្តអធ្យាស្រ័យ និង ដោយសេរីភាពរបស់គាត់ អាចបង្ហាញឲ្យឃើញយ៉ាងខ្លាំងក្លាឡើង ។

ដូច្នេះសំបុត្រនេះគឺមានតម្លៃមិនមែនគ្រាន់តែសំរាប់ការបង្រៀននូវ *អ្វី* ត្រឹមត្រូវដែលត្រូវធ្វើនោះទេ ប៉ុន្តែក៏ជាវិធីដើម្បីឈោងចាប់មនុស្សឲ្យអនុវត្តតាមមេរៀននេះដែរ ។ ពីព្រោះការសរសើររបស់ប៉ូលចំពោះ ភីលេម៉ូន គឺសមនឹងទទួលហើយនិងស្មោះត្រង់គឺមិនជាការកុហកឬ ការបញ្ចោរខុសឆ្គងនោះទេ ។ ក្នុងឋានៈជាអ្នកដឹកនាំដ៏រឹងមាំ មានសេរីភាពនឹងសរសើរមនុស្សរបស់គាត់នៅពេលណា ដែលសមរម្យនិងពង្រឹងឲ្យរឹងមាំឡើងតែគាត់មិនតម្កើងខ្លួនឯងខ្ពស់លើសពួកគេនិងទាំងមិនរុញពួកគេឲ្យធ្លាក់ចុះដែរ ។ តើពួកជំនុំជាច្រើនគប្បីដើរតួនាទីឲ្យល្អប្រសើរឡើងប៉ុណ្ណាទៀត ប្រសិនបើអ្នកដឹកនាំរបស់ពួកជំនុំអាចប្រើទេព្យកោសល្យដែលបានបង្ហាញភស្តុតាងក្នុងសំបុត្ររបស់លោកប៉ូល ដែលផ្ញើទៅកាន់លោក ភីលេម៉ូន ។

**ការពោលអះអាងចំពោះន័យជំនួសនៃពាក្យ** Hyper ។ ព្រះគម្ពីរសញ្ញាថ្មីជាភាសាក្រិច ជាញឹកញាប់ប្រើពាក្យឈ្នាប់ Hyper ដើម្បីនិយាយពីការសុគត របស់ព្រះគ្រីស្ទដើម្បីសង្គ្រោះលោកិយ[២៨] ពេលខ្លះបាននិយាយ ពីពាក្យឈ្នាប់ Hyper ថានេះមានន័យត្រឹមតែ "សំរាប់ផលប្រយោជន៍ និង ក្នុងនាម" ហើយមិនដែលមានន័យថា គំនិតយកមកជំនួស "ជាជំនួស, ជំនួសឲ្យ" ដូច្នេះការសុគតរបស់ព្រះគ្រីស្ទអាចមានផលប្រយោជន៍ ដោយប្រការណាមួយដល់លោកិយ ដោយមិនបានធ្វើត្រង់កន្លែងរបស់ពាក្យនោះសោះ ។ ទោះជាយ៉ាងណាក៏ លោក ប៉ូល ប្រើ ពាក្យឈ្នាប់ Hyper ក្នុង ភីលេម៉ូនខ ១៣ នៅពេលដែលគាត់

---

[២៨] *ឧទាហរណ៍ ម៉ាកុស ១៤:២៤; យ៉ូហាន ១០:១១,១៥, ៥០-៥២, ១៥:១៣, ១៨:១៤; រ៉ូម ៥:៦-៨ ។ល។*

និយាយថា "ខ្ញុំចង់ឲ្យគាត់នៅជាមួយ នឹងខ្ញុំណាស់ ដើម្បីឲ្យគាត់បំរើខ្ញុំជំនួសអ្នក . . ." ។ យ៉ាងច្បាស់លាស់ណាស់ ពាក្យឈ្នាប់ Hyper ត្រូវបានប្រើនៅទីនេះ ក្នុងគំនិតជំនួស ។ ការបំរើរបស់ អូនេស៊ីម នោះ លោក ប៉ូល អាចគ្មានផ្លូវមានផលប្រយោជន៍ដល់ ភីលេម៉ូន ឡើយ ។ តាមការពិត នឹងមានភាពងាយស្រួលដល់គាត់ ដោយដកហូតគាត់ចេញពីការបំរើក្នុងឋានៈជាទាសកររបស់ខ្លួន ។ លោក ប៉ូល កំពុងបញ្ជាក់ថា គាត់មានឱកាសដ៏ល្អ គឺលោក ភីលេម៉ូន គប្បីបំរើ លោក ប៉ូល ដោយផ្ទាល់នៅក្នុងគុក ។ ប៉ុន្តែចាប់តាំងពីលោក ភីលេម៉ូន មិននៅទីនោះ គឺលោក អូនេស៊ីម អាចបំរើជំនួសគាត់ ។

ទោះបីជាយ៉ាងដូច្នេះក៏ដោយ យើងអាច ឬ មិនអាចបង្ខំឲ្យបានយល់ពាក្យឈ្នាប់ Hyper ដោយគំនិតជំនួសគ្រប់ពេលវេលាឡើយ ដែលវានិយាយអំពីការសុគតរបស់ព្រះគ្រីស្ទ ដែលអត្ថន័យនោះត្រូវតែបំរើជាយ៉ាងហោចណាស់ ជាពាក្យស័ព្ទដែលអាចកើតបាន និង ដែលអាចជួយឧបត្ថម្ភបាន ។

*លទ្ធិគ្រប់ជ្រុងជ្រោយ និង រឿងរ៉ាវសង្គម* ។ ជំនឿរបស់គ្រីស្ទបរិស័ទម្នាក់ៗគប្បីមានឥទ្ធិពលនៅគ្រប់ចំណុចនៃជីវិតរបស់គាត់ ។ ព្រះគម្ពីរប៊ីបមិនបានលើកទឹកចិត្តយើងឲ្យ "ជឿ" លើជំនឿរបស់យើង ដែលគ្រាន់តែស្ថិតក្នុងគំនិតរបស់យើងខ្លះ ប៉ុន្តែជាជាងអនុញ្ញាតឲ្យវាធ្វើឲ្យមានរូបរាងឡើងពីរបៀបដែលយើងគិតនិង ធ្វើសកម្មភាពឆ្ពោះទៅកាន់គ្រប់ទាំងរឿងរ៉ាវនោះ ។ ដូច្នេះរបស់ភីលេម៉ូនដែលមិនមែនជាការអនុវត្តន៍តាមការប្រព្រឹត្តរបស់ពួករ៉ូមនៅបច្ចុប្បន្ននោះទេ គប្បីកំណត់ឲ្យដឹងពីរបៀបដែលគាត់ប្រព្រឹត្តចំពោះទាសករអូនេស៊ីមដែលលួចរត់ចេញ ។ ជំនឿរបស់អ្នកគ្រីស្ទបរិស័ទ គឺគ្រប់ជ្រុងជ្រោយដែលគប្បីមានឥទ្ធិពលឬណែនាំគ្រប់ទាំងទិដ្ឋភាពនៃជីវិតរបស់អ្នកជឿ ។ សំបុត្រដ៏ខ្លីនេះបំភ្លឺសេចក្តីពិតនោះឯង ។

ប៉ុន្តែលោក ភីលេម៉ូន ក៏បំភ្លឺផងដែរពីគំរូព្រះគម្ពីរសញ្ញាថ្មីចំពោះការប្រឈមទៅនឹងបញ្ហាសង្គមក្នុងសង្គមដ៏ធំនោះ ។ ទាសភាព-ដូចជាត្រូវបានអនុវត្តយ៉ាងពិសេសនៅក្នុងសង្គមរបស់អ្នកមិនជឿព្រះគ្រីស្ទ ដែលមិនត្រូវបានបញ្ញត្តិ ដោយក្រិត្យវិន័យរបស់លោក ម៉ូសេ-បានសេចក្តីថាកំពុងបន្ទាបបន្ថោកដល់មនុស្សជាតិ ដែលបានបង្កើតមកក្នុងរូបអង្គនៃព្រះ ដូចជាការជញ្ជក់ផលប្រយោជន៍ រំលោភបំពាន(ឃោរឃៅ) និងអំពើកំរោល ។ បានកើតឡើងរាប់សតវត្សមកហើយ នូវសម្រែកដ៏ឈឺចាប់ ដើម្បីសុំឲ្យលុបបំបាត់ចោល ។

យ៉ាងណាក៏ដោយព្រះគម្ពីរសញ្ញាថ្មីទាំងមូល និង ព្រះគម្ពីរភីលេម៉ូននៅក្នុងការនិយាយពិសេសបានចែងថា គ្មានអ្វីសោះស្តីអំពីការទទួលខុសត្រូវរបស់អ្នកគ្រីស្ទានក្នុងការរំលំប្រព័ន្ធទាសភាព ។ គ្មានការប្តឹងតវ៉ា គ្មានបានសរសេរលិខិតអ្វីសោះ គ្មានការបង្កើតគណៈកម្មាធិការ គ្មានការប្តឹងតវ៉ាទៅរដ្ឋាភិបាល ។ លោក ប៉ូល និយាយយ៉ាងងាយថា "ភីលេម៉ូនត្រូវប្រព្រឹត្តចំពោះទាសករ របស់អ្នកដូច ជាបងប្អូនខាងគ្រីស្តបរិស័ទ" កន្លែងដទៃទៀត គាត់ជម្រុញទាសករឲ្យបំរើ ដោយស្មោះត្រង់ និងម្ចាស់ទាសករឲ្យប្រព្រឹត្តចំពោះទាសករដោយយុត្តិធម៌[២៥] គ្រីស្តបរិស័ទត្រូវធ្វើទង្វើក្នុងគ្រប់ទាំងចំណុចនៃជីវិតរបស់ពួកគេ ក្នុងឋានៈជាអ្នកគ្រីស្តបរិស័ទ ហើយពួកជំនុំត្រូវតែអនុវត្តប្រការនេះទៅក្នុងគ្រប់ ទាំងមធ្យោបាយរបស់គ្រីស្តបរិស័ទ ប៉ុន្តែសង្គមជាទូទៅមិនដែលផ្តោតលើការទូន្មាន

---

*[២៥] ឧទាហរណ៍ អេភេសូ ៦:៥-៩; កូល៉ុស ៣:២២-៤១; ១ធីម៉ូថេ ៦:១-២; ទីតុស ២:១៨; ១ពេត្រុស ២:១៨ បើសិនជាទាសករបានមកឯព្រះគ្រីស្ទនោះ គាត់មិនត្រូវបង្កើតសេចក្តីប្រាថ្នាជាជំបូងរបស់គាត់ ដើម្បីចៀសវាងពីទាសភាពឡើយ ប៉ុន្តែជាជាងនោះ គឺបំរើព្រះគ្រីស្ទនៅកន្លែងណា ដែលគាត់នៅ (១កូរិនថូស ៧:២១-២៣) ហេតុផលមួយសំរាប់ការនេះគឺថាទាសករ និង អ្នកជាគឺស្មើគ្នាក្នុងព្រះគ្រីស្ទ (១កូរិនថូស ១២:១៣; កាឡាទី ៣:២៨; កូល៉ុស ៣:១១)*

របស់ព្រះគម្ពីរសញ្ញាថ្មីឡើយ ។ ព្រះយេស៊ូវអង្គឯងមិនបានប៉ុនប៉ង ឬណែនាំអ្នកដទៃឲ្យធ្វើជាអ្នកកែតម្រង់សង្គមអ្នកមិនជឿឡើយ ឬពួកសាវ័កក៏មិនតាំងចិត្តដូច្នេះដែរ ។ យើងជាអំបិល និងជាពន្លឺដែលបង្ហាញដោយគំរូ និងដោយបង្កើតការស្រេក មិនដោយការវាយដំ និងទារុណកម្មក្នុងការបង្ខំដល់អ្នកមិនជឿឲ្យជឿតាមនោះឡើយ ។ លោកប៉ូលបញ្ជាក់យ៉ាងច្បាស់លាស់ថា តើកិច្ចការរបស់ពួកជំនុំមិនមែនជាកិច្ចការរបស់រដ្ឋាភិបាលស៊ីវិលទេឬអ្វី: "តើអ្វីទៅជាកិច្ចការរបស់ខ្ញុំក្នុងការជំនុំជំរះដល់អស់អ្នកនៅក្រៅពួកជំនុំ? តើអ្នកមិនជំនុំជំរះមនុស្សនៅខាងក្នុងពួកជំនុំទេឬអ្វី? ព្រះទ្រង់ជំនុំជំរះពួកអ្នកខាងក្រៅ" (១កូរិនថូស ៥:១២-១៣) ។

តើអ្នកគ្រីស្ទានបានឃោសនាប្រឆាំងនឹងទាសភាព-ឬបញ្ហាអ្វីទៀតនៅក្នុងសង្គមរ៉ូម៉ាំងនោះឡើយ ការធ្វើបែបនោះអាចនឹងត្រូវបានធ្វើឲ្យភាន់ច្រឡំដំណឹងល្អ ។ ម្យ៉ាងទៀតក្រៅពីព្រះគុណរបស់ព្រះអាចបង្ហាញការសម្លាប់ខ្លួន បើសិនទាសករត្រូវបានលើកទឹកចិត្តឲ្យដើរតាមផ្លូវនោះដើម្បីបះបោរ ។ វិធីសាស្ត្ររបស់គ្រីស្តបរិស័ទ គឺដើម្បីផ្លាស់ប្តូរចិត្តរបស់មនុស្ស ហើយបន្ទាប់មកបង្រៀនអ្នកដែលបានជឿ (ម្នាក់ៗនិងពួកជំនុំ) ពីរបៀបដែលផ្លាស់ប្តូរ គប្បីសម្តែងខ្លួនក្នុងគ្រប់ទំនាក់ទំនង ។ ព្រះគម្ពីរសញ្ញាថ្មីបង្រៀនការបង្កើតសិស្សម្នាក់ៗ និង ពួកជំនុំហើយដឹងថាគ្មានអ្វីក្រៅពីការបង្កើតសិស្សប្រជាជាតិដូចគ្នាទេ ។ ទោះជាគ្រីស្ទានអាចនឹងគប្បីត្រូវធ្វើការសំរាប់ការល្អដល់សង្គមក៏ដោយ ក៏ព្រះគម្ពីរភីលេម៉ូនរំលឹកដល់យើងពីវិធីសាស្ត្រដំបូង និងជាសេចក្តីណែនាំ ។

## សេចក្តីបន្ថែម: ការរៀបចំនៃព្រះគម្ពីរភីលេម៉ូន[២៦] តាមលក្ខណៈឆ្លុះ

ក. ១-៣ លក្ខណៈនៃសំបុត្រ

ក ១.២ ឈ្មោះពួកអ្នកដែលនៅជាមួយលោកភីលេម៉ូន

ខ ៣ ការប្រសិទ្ធិពរ

ខ ៤-៧ សេចក្តីអធិស្ឋានរបស់ប៉ូលសំរាប់ភីលេម៉ូន ។ បដិសណ្ឋារកិច្ចរបស់ភីលេម៉ូន

គ ៨ អំណាច

ឃ ៩.១០ ការទូលអង្វរករ

ង ១០ អូនេស៊ីមជាម្នាក់ដែលប៉ូលនាំ ប្រែចិត្ត ។

ច ១១.១២ ធ្វើខុសដោយអូនេស៊ីម ។ កែខៃបានធ្វើឡើងដោយលោកប៉ូល

ជ ១២ ឲ្យទទួលអូនេស៊ីមដូចទទួលលោកប៉ូល

ឈ ១៣.១៤ ប៉ូលនិងភីលេម៉ូន

ញ ១៥ អូនេស៊ីម

*ញ* ១៦ អូនេស៊ីម

*ឈ* ១៦ ប៉ូលនិងភីលេម៉ូន

*ជ* ១៧ ឲ្យទទួលអូនេស៊ីមដូចទទួលលោកប៉ូល

ច ១៨.១៩ ការធ្វើខុសដោយអូនេស៊ីម ។ កែខៃបានធ្វើឡើងដោយលោកប៉ូល

*ង* ១៩ អូនេស៊ីមជាម្នាក់ដែលប៉ូលនាំ ប្រែចិត្ត

*ឃ* ២០ ការទូលអង្វរ

គ ២១ អំណាច

ខ ២២ ការទទួលរាក់ទាក់របស់ភីលេម៉ូន ។ សេចក្តីអធិស្ឋានរបស់ភីលេម៉ូនសំរាប់ប៉ូល

ក ២៣-២៥ លក្ខណៈនៃសំបុត្រ

ក ២៣.២៤ ឈ្មោះពួកអ្នកដែលនៅជាមួយលោកប៉ូល

ខ ២៥ ការប្រសិទ្ធិពរ

---

(២៦) *ដកស្រង់ចេញពីក្នុងសៀវភៅឈ្មោះ* E. W. Bullinger Figures of Speech Used in the Bible Explained and Illustrated (London: Messrs. Eyre and Spottiswoode, 1898; reprinted., Grand Rapids: Baker, 1968), 379.